## ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

លេខ ០០៩៣ អបស/ឱអបស

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ ០២ ឆ្នាំ២០០៩

# ប្រកាស

## ស្តីពី

## ការកែសម្រួលប្រកាសលេខ ៨៣ អបស/ឱអបស ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ១៩៩៩ របស់ក្រសួងសុខាភិបាល ស្តីពី លក្ខខណ្ឌក្នុងការផ្សព្វផ្សាយឱសថ និងផលិតផល ដែលមានគុណភាពក្នុងការបង្ការ ឬព្យាបាលជម្ងឺ

## រដ្ឋមន្ត្រី ក្រសួងសុខាភិបាល

-បានឃើញ រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ កញ្ញា ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រម នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ មករា ១៩៩៦ ប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសុខាភិបាល

-បានឃើញ ព្រះរាជក្រម ជស/រកម/០៦៩៦/០២ ចុះថ្ងៃទី ១៧ មិថុនា ១៩៩៦ ប្រកាសឱ្យប្រើច្បាប់ ស្តីពី ការគ្រប់គ្រងឱសថ

-បានឃើញ ព្រះរាជក្រម នស/រកម/១២០៧/០៣៧ ចុះថ្ងៃទី ២៨ ធ្នូ ២០០៧ ប្រកាសឱ្យប្រើច្បាប់ ស្តីពី វិសោធនកម្ម ច្បាប់ ស្តីពី ការគ្រប់គ្រងឱសថ

-បានឃើញ អនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ២២ តុលា ១៩៩៧ ស្តីពី ការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសុខាភិបាល

-បានឃើញ អនុក្រឹត្យលេខ ១២២អនក្រ.បក ចុះថ្ងៃទី ២៨ សីហា ២០០៨ ស្តីពីការគ្រប់គ្រងគ្រឿងសម្អាង

-បានឃើញ ប្រកាសរបស់ក្រសួងសុខាភិបាល លេខ ៨៣ អបស/ឱអបស ចុះថ្ងៃទី ៣១ មីនា ១៩៩៩ ស្តីពី លក្ខខណ្ឌក្នុងការផ្សព្វផ្សាយឱសថ និងផលិតផល ដែលមានគុណភាពក្នុងការបង្ការ ឬព្យាបាលជម្ងឺ

-និងយោងតាមការចាំបាច់របស់ក្រសួងសុខាភិបាល ។

## ស ម្រេ ច

**ប្រការ១ :** ខ្លឹមសារប្រកាសលេខ ៨៣ អបស/ឱអបស ចុះថ្ងៃទី ៣១ ខែមីនា ឆ្នាំ ១៩៩៩ របស់ក្រសួងសុខាភិបាលត្រូវបានកែសម្រួលដូចខាងក្រោម ។

**ប្រការ២ :** ការផ្សព្វផ្សាយពាណិជ្ជកម្មឱសថសម័យ ឱសថបូរាណ ផលិតផលបំប៉នសុខភាព ស្រាថ្នាំបូរាណគ្រប់ប្រភេទ សម្ភារៈបរិក្ខារពេទ្យ-ទន្តពេទ្យ សម្ភារៈប្រតិករសម្រាប់មន្ទីរពិសោធន៍វេជ្ជសាស្ត្រ-ឱសថសាស្ត្រ-ទន្តសាស្ត្រ គ្រឿងសម្អាង និងផលិតផលដែលមានគុណភាពក្នុងការបង្ការ ឬព្យាបាលជម្ងឺ តាមរយៈទូរទស្សន៍ វិទ្យុ សារព័ត៌មាន ទស្សនាវដ្តី ព្រឹត្តិប័ត្រវេជ្ជសាស្ត្រ-ឱសថសាស្ត្រ-ទន្តសាស្ត្រ ប័ណ្ណប្រកាសរូបភាព សិក្ខាសាលា ទិវាវេជ្ជសាស្ត្រ-ឱសថសាស្ត្រ-ទន្តសាស្ត្រ ឬតាមរូបភាពផ្សេងៗទៀតអាចប្រព្រឹត្តទៅបាន លុះត្រាតែ មានការអនុញ្ញាតពីក្រសួងសុខាភិបាល ។



ទីស្តីការរដ្ឋមន្ត្រីក្រសួងសុខាភិបាល, លេខ ១៥១-១៥៣ វិថីកម្ពុជាក្រោម ភ្នំពេញ ទូរស័ព្ទ (៨៥៥-២៣) ៤២៦ ០៣៤ / ៤២៦ ៨៤១ ទូរសារ: (៨៥៥-២៣) ៧២២ ៩៣៣

ប្រការ៣ : ឱសថ ផលិតផលបំប៉នសុខភាព បរិក្ខារពេទ្យ គ្រឿងសម្អាង និងផលិតផលដែលមានគុណភាពក្នុងការបង្ការ ឬព្យាបាលជម្ងឺ អាចសុំធ្វើការផ្សព្វផ្សាយបាន លុះត្រាតែមានវិញ្ញាបនប័ត្រទិដ្ឋាការ ឬបញ្ជិកា ឬប្រវេទន៍ចេញដោយក្រសួងសុខាភិបាល ។

ប្រការ៤ : ចំពោះឱសថសម័យ ឱសថបូរាណ លក់ដោយមិនចាំបាច់មានវេជ្ជបញ្ជា(OTC) ស្រាថ្នាំបូរាណគ្រប់ប្រភេទ ផលិតផលបំប៉នសុខភាព សម្ភារៈបរិក្ខារពេទ្យ-ទន្តពេទ្យ សម្ភារៈប្រតិករសម្រាប់មន្ទីរពិសោធន៍វេជ្ជសាស្ត្រ-ឱសថសាស្ត្រ-ទន្តសាស្ត្រ គ្រឿងសម្អាង និង ផលិតផលអនាម័យ សាម៉ីជនអាចសុំធ្វើការផ្សព្វផ្សាយបានតាមទូរទស្សន៍ វិទ្យុ សារព័ត៌មាន ទស្សនាវដ្ដី ឬប័ណ្ណប្រកាសរូបភាព ដែលមានទំហំត្រឹមក្រដាស $A_4$ សំរាប់ចែកដល់អ្នកបច្ចេកទេសសុខាភិបាល និងដាក់តាមគ្លីនិក ឱសថស្ថាន ឱសថស្ថានរង សម្រាប់អតិថិជនបានយល់ដឹង ប្រតិទិន សម្ភារៈប្រើប្រាស់ផ្សេងៗមានជាអាទិ៍ កែវទឹក នាឡិកា ។ល។ និងសម្ភារៈការិយាល័យគ្រប់ប្រភេទ ។

ប្រការ៥ : ចំពោះផលិតផលបំប៉នសុខភាព សម្ភារៈ បរិក្ខារពេទ្យ-ទន្តពេទ្យ សម្ភារៈប្រតិករសម្រាប់មន្ទីរពិសោធន៍វេជ្ជសាស្ត្រ-ឱសថសាស្ត្រ-ទន្តសាស្ត្រ គ្រឿងសម្អាង និង ផលិតផលអនាម័យ ដែលពុំមានគុណវិបត្តិធ្ងន់ធ្ងរដល់អ្នកប្រើប្រាស់ សាម៉ីជនអាចសុំធ្វើការផ្សព្វផ្សាយបានតាមផ្ទាំងរូបភាពធំៗ (Panneau) ទំហំ ៤ម៉ែត្រ គុណ ៨ម៉ែត្រ ។

ប្រការ៦ : ចំពោះឱសថដែលផ្សំឡើងដោយសារធាតុមានគ្រោះថ្នាក់ (លក់ត្រូវមានវេជ្ជបញ្ជា) ឱសថញៀន ឱសថប្រព័ន្ធសរសៃប្រសាទ ឱសថពន្លូតកូន (abortifs ) ឱសថព្យាបាលជម្ងឺកាមរោគ អេដស៍ មហារីក ឱសថប្រើសំរាប់តែទារក ឱសថបង្កើនកណ្ហា (aphrodisiaque ) សាម៉ីជនមិនអាចសុំធ្វើការផ្សព្វផ្សាយតាមទូរទស្សន៍ វិទ្យុ សារព័ត៌មាន ទស្សនាវដ្ដី ឬប្រតិទិនបានទេ ។ ការផ្សព្វផ្សាយផលិតផលខាងលើ ដល់អ្នកបច្ចេកទេសសុខាភិបាល អាចធ្វើបានតាមរយៈសិក្ខាសាលា ទិវាវេជ្ជសាស្ត្រ-ឱសថសាស្ត្រ-ទន្តសាស្ត្រ ឬ ព្រឹត្តិប័ត្រវេជ្ជសាស្ត្រ-ឱសថសាស្ត្រ-ទន្តសាស្ត្រ ឬប័ណ្ណប្រកាសរូបភាព (Brochure) ដែលមានទំហំត្រឹមក្រដាស $A_4$ សម្ភារៈប្រើប្រាស់ផ្សេងៗ និងសម្ភារៈការិយាល័យគ្រប់ប្រភេទ ដោយគ្រាន់តែដាក់ឈ្មោះឱសថ សំរាប់ចែកដល់អ្នកបច្ចេកទេសសុខាភិបាល ។

ប្រការ៧ : អត្ថបទ និងរូបភាពដែលពាក់ព័ន្ធនឹងការផ្សព្វផ្សាយពាណិជ្ជកម្មឱសថសម័យ ឱសថបូរាណ ផលិតផលបំប៉នសុខភាព ស្រាថ្នាំបូរាណគ្រប់ប្រភេទ សម្ភារៈបរិក្ខារពេទ្យ-ទន្តពេទ្យ សម្ភារៈប្រតិករសម្រាប់មន្ទីរពិសោធន៍វេជ្ជសាស្ត្រ-ឱសថសាស្ត្រ-ទន្តសាស្ត្រ គ្រឿងសម្អាង និងផលិតផលដែលមានគុណភាពក្នុងការបង្ការ ឬព្យាបាលជម្ងឺ តាមរយៈទូរទស្សន៍ វិទ្យុ សារព័ត៌មាន ទស្សនាវដ្ដី ព្រឹត្តិប័ត្រវេជ្ជសាស្ត្រ-ឱសថសាស្ត្រ-ទន្តសាស្ត្រ ប័ណ្ណប្រកាសរូបភាព សិក្ខាសាលា ទិវាវេជ្ជសាស្ត្រ-ឱសថសាស្ត្រ-ទន្តសាស្ត្រ ឬតាមរូបភាពផ្សេងៗទៀត ត្រូវឆ្លងការត្រួតពិនិត្យ និងមានការឯកភាពពីក្រសួងសុខាភិបាល ។ ខ្លឹមសារផ្សព្វផ្សាយត្រូវមានលក្ខណៈត្រឹមត្រូវតាមឯកសារវេជ្ជសាស្ត្រ-ឱសថសាស្ត្រ-ទន្តសាស្ត្រ និង ជៀសវាងការឃោសនាបំផ្លើស ប្រាសចាកខុសពីខ្លឹមសារដែលមានការយល់ព្រមពីក្រសួងសុខាភិបាល ។

454

ប្រការ៨ : ការសុំផ្សព្វផ្សាយពាណិជ្ជកម្មឱសថ ផលិតផលបំប៉នសុខភាព គ្រឿងសម្អាង បរិក្ខារពេទ្យ ត្រូវបំពេញសំណុំលិខិតដូចខាងក្រោម :

ក-ករណីផ្សព្វផ្សាយតាមទូរទស្សន៍ ឬវិទ្យុ

| | |
|---|---|
| -ពាក្យសុំផ្សព្វផ្សាយ និង កិច្ចសន្យា | ១ ច្បាប់ ( មានគំរូ ) |
| -វិញ្ញាបនប័ត្រ ទិដ្ឋាការ បញ្ជិកា ឬប្រវេទន៍ ( ថតចម្លង) | ១ ច្បាប់ |
| -សេចក្តីព្រាងអត្ថបទផ្សព្វផ្សាយ | ១ ច្បាប់ |
| -កាសែតវីដេអូ DVD ឬ VCD ឬ CD ជា Spot គំរូ | ១ ឯកតា |
| -ឱសថគំរូព្រមទាំងបរិយាយប័ណ្ណឱសថជាភាសាខ្មែរ | ១ ឯកតា |

ខ-ករណីផ្សព្វផ្សាយតាមសារព័ត៌មាន ឬទស្សនាវដ្តី ឬប្រតិទិន ឬសៀវភៅផ្សព្វផ្សាយពាណិជ្ជកម្មផ្សេងៗ ឬប័ណ្ណប្រកាសរូបភាព

| | |
|---|---|
| -ពាក្យសុំផ្សព្វផ្សាយ និង កិច្ចសន្យា | ១ ច្បាប់ ( មានគំរូ ) |
| -វិញ្ញាបនប័ត្រ ទិដ្ឋាការ បញ្ជិកា ឬប្រវេទន៍ ( ថតចម្លង) | ១ ច្បាប់ |
| -សេចក្តីព្រាងអត្ថបទ និងរូបភាពផ្សព្វផ្សាយ | ១ ច្បាប់ |
| -ឱសថគំរូព្រមទាំងបរិយាយប័ណ្ណឱសថជាភាសាខ្មែរ | ១ ឯកតា |

គ-ករណីធ្វើសិក្ខាសាលា ឬប្រជុំតុមូល

| | |
|---|---|
| -ពាក្យសុំផ្សព្វផ្សាយ | ១ ច្បាប់ ( មានគំរូ ) |
| -វិញ្ញាបនប័ត្រ ទិដ្ឋាការ បញ្ជិកា ឬប្រវេទន៍ ( ថតចម្លង) | ១ ច្បាប់ |
| -កម្មវិធី | ១ ច្បាប់ |

ប្រការ៩ : លិខិតអនុញ្ញាតផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ សារព័ត៌មាន ទស្សនាវដ្តី មានសុពលភាពរយៈពេល ៦ខែ លើកលែងតែប្រតិទិនដែលមានសុពលភាព ១ឆ្នាំ ។ សាម៉ីជនអាចសុំបន្តការផ្សព្វផ្សាយសារឡើងវិញ ១ខែមុនពេលអស់សុពលភាព ។

ប្រការ១០ : ការផ្សព្វផ្សាយដែលត្រូវហាមឃាត់ :

-ប្រើឧឃោសនស័ព្ទតាមទីសាធារណៈ រោងល្ខោន រោងកុន ផ្សារណាត់
-បិទតាមទូទូរស័ព្ទសាធារណៈ មធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទ
-បោះពុម្ពលើអាវយឺត អាវភ្លៀង ឆ័ត្រ មួក
-ធ្វើជាបដាចងកាត់ទទឹងថ្នល់ តាមបង្គោលភ្លើង ឬទីសាធារណៈ ឬតាមអាគារផ្សេងៗ
-បិទលើឆាកពេលប្រគុំតន្ត្រី ពេលធ្វើសម្ភាសន៍ ឬក្នុងកម្មវិធីផ្សេងៗ តាមប៉ុស្តិ៍ទូរទស្សន៍នានា
-បិទក្បែរស្លាកសញ្ញាឱសថស្ថាន-រង ឬធ្វើជាស្លាកសញ្ញាឱសថស្ថាន-រង

455

-បិទតាមទូថ្នាំ ជារនាំងចាំងថ្ងៃ ជាប្រអប់ភ្លើង ជាផ្ទាំងរូបភាពបិទ ឬបញ្ឈរមុខឱសថស្ថាននិងគ្រឹះស្ថាន ផ្សេង១ទៀត

-ការសម្ភាសន៍របស់ពិធិករ ពិធីការិនី តាមវិទ្យុ ទូរទស្សន៍ និងតាមគ្រប់រូបភាពដែលមានបំណងផ្សព្វផ្សាយ ពាណិជ្ជកម្ម

-ការធ្វើអត្ថាធិប្បាយបន្ថែម របស់ សិល្បៈករ សិល្បៈការិនី ពិធីករ ពិធីការិនី

-ឬតាមរូបភាពផ្សេង១ទៀត ដែលគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល ។

ប្រការ១១ : ក្រសួងសុខាភិបាលមានសិទ្ធិដកហូតវិញនូវលិខិតអនុញ្ញាតផ្សព្វផ្សាយ ក្នុងករណីពិនិត្យឃើញថា

-ខ្លឹមសារ និងរូបភាពផ្សព្វផ្សាយមានលក្ខណៈខុសពីការយល់ព្រមរបស់ក្រសួងសុខាភិបាល

-ឬផលិតផលនោះអាចបង្កគ្រោះថ្នាក់ដល់សុខភាពតាមការផ្ដល់ព័ត៌មានពីក្រសួងមានសមត្ថកិច្ច ។

ប្រការ១២ : ការប្រព្រឹត្តល្មើសនឹងប្រកាសនេះត្រូវផ្ដន្ទាទោសតាមទោសបញ្ញត្តិដែលមានចែងក្នុងច្បាប់ ស្ដីពីការគ្រប់គ្រងឱសថ ។

ប្រការ១៣ : អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល អគ្គាធិការដ្ឋាន នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យនិងគ្រឿងសំអាង មានភារកិច្ចត្រួតពិនិត្យតាមដានការអនុវត្តន៍ប្រកាសនេះអោយមានប្រសិទ្ធភាពតាមភារកិច្ចរៀងខ្លួន ។

ប្រការ១៤ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ១៥ : ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ម៉ម_ប៊ុនហេង

ចម្លងជូន :

-អគ្គលេខាធិការដ្ឋាន រដ្ឋសភា
-ទីស្ដីការគណៈរដ្ឋមន្ត្រី
-ក្រសួងពត៌មាន
-សាលាក្រុងភ្នំពេញ
-អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល
-អគ្គនាយកដ្ឋានរដ្ឋបាល-ហិរញ្ញវត្ថុ
-អគ្គាធិការដ្ឋានក្រសួងសុខាភិបាល
-នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង
-មន្ទីរសុខាភិបាលរាជធានី និងខេត្ត-ក្រុង
-ឯកសារ
-កាលប្បវត្តិ